**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ដើម្បីជានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាពការងារ និងការបង្កើនផលិតភាពក្នុងរដ្ឋបាលសាធារណៈ។

**មាត្រា២ ._**

អនុក្រឹត្យនេះ មានគោលដៅ ៖

- រៀបចំកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលក្នុងវិស័យរដ្ឋបាល អប់រំ សុខាភិបាល បច្ចេកទេស និងការទូត
- កំណត់ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងារ ប្រាក់បង្គ្រប់ ប្រាក់ហានិភ័យតំបន់ ប្រាក់ហានិភ័យសុខភាព និងប្រាក់គរុកោសល្យបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិល។

**មាត្រា៣ ._**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលនិងមន្ត្រីកម្មសិក្សាដែលស្ថិតនៅក្រោមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ប្រាក់បំណាច់មុខងារ

**មាត្រា៤ ._**

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមលើបៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញមុខងារក្នុងមុខតំណែងតាមរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។ ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំនិងកំណត់ដូចខាងក្រោម ៖

១. វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គលេខាធិការរាជរដ្ឋាភិបាល | ១ ៧៥០ ០០០ |
| ២ | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ១ ៤០០ ០០០ |
| ៣ | អគ្គលេខាធិការនៃក្រសួង ស្ថាប័ន | ១ ០០០ ០០០ |
| ៤ | អគ្គនាយក | ៩៣០ ០០០ |
| ៥ | អគ្គាធិការ | ៩២០ ០០០ |
| ៦ | អភិបាលរាជធានី ខេត្ត | ៩១០ ០០០ |
| ៧ | អគ្គលេខាធិការរងនៃក្រសួង ស្ថាប័ន | ៨៨០ ០០០ |
| ៨ | អគ្គនាយករង | ៨៥០ ០០០ |
| ៩ | អគ្គាធិការរង | ៨៣០ ០០០ |
| ១០ | អភិបាលរងរាជធានី ខេត្ត | ៨២០ ០០០ |
| ១១ | ប្រធាននាយកដ្ឋាន | ៨២០ ០០០ |
| ១២ | អធិការថ្នាក់កណ្ដាល | ៧៩០ ០០០ |
| ១៣ | នាយករដ្ឋបាលសាលារាជធានី ខេត្ត | ៧៩០ ០០០ |
| ១៤ | អនុប្រធាននាយកដ្ឋាន | ៧១០ ០០០ |
| ១៥ | ប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្ដាល) | ៧១០ ០០០ |

| | | |
|---|---|---|
| ១៦ | អភិបាលក្រុង ស្រុក ខណ្ឌ | ៧០០ ០០០ |
| ១៧ | អធិការរដ្ឋបាលព្រៃឈើ | ៧០០ ០០០ |
| ១៨ | អធិការរដ្ឋបាលជលផល | ៧០០ ០០០ |
| ១៩ | នាយករងរដ្ឋបាលសាលារាជធានី ខេត្ត | ៧០០ ០០០ |
| ២០ | ប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៧០០ ០០០ |
| ២១ | អធិការរងថ្នាក់កណ្តាល | ៧០០ ០០០ |
| ២២ | ក្រឡាបញ្ជី | ៦៨០ ០០០ |
| ២៣ | ប្រធានការិយាល័យថ្នាក់កណ្តាល | ៣៩០ ០០០ |
| ២៤ | អនុប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្តាល) | ៣៩០ ០០០ |
| ២៥ | អភិបាលរងក្រុង ស្រុក ខណ្ឌ | ៣២០ ០០០ |
| ២៦ | នាយកទីចាត់ការសាលារាជធានី ខេត្ត | ៣២០ ០០០ |
| ២៧ | អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៣២០ ០០០ |
| ២៨ | ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ៣២០ ០០០ |
| ២៩ | នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ៣២០ ០០០ |
| ៣០ | អនុប្រធានការិយាល័យថ្នាក់កណ្តាល | ២២០ ០០០ |
| ៣១ | នាយករងទីចាត់ការសាលារាជធានី ខេត្ត | ២២០ ០០០ |
| ៣២ | អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ២២០ ០០០ |
| ៣៣ | នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ២២០ ០០០ |
| ៣៤ | ប្រធានការិយាល័យសាលារាជធានី ខេត្ត | ២២០ ០០០ |
| ៣៥ | ប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២២០ ០០០ |
| ៣៦ | អនុប្រធានការិយាល័យសាលារាជធានី ខេត្ត | ២០០ ០០០ |
| ៣៧ | ប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ២០០ ០០០ |
| ៣៨ | ប្រធានអង្គភាពលទ្ធកម្ម ក្រុង ស្រុក ខណ្ឌ | ២០០ ០០០ |
| ៣៩ | អនុប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២០០ ០០០ |
| ៤០ | ប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ២០០ ០០០ |
| ៤១ | អនុប្រធានអង្គភាពលទ្ធកម្ម ក្រុង ស្រុក ខណ្ឌ | ១៨០ ០០០ |
| ៤២ | អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ១៨០ ០០០ |
| ៤៣ | អនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ១៨០ ០០០ |
| ៤៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ឬមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬមន្ត្រីការទូតជាន់ខ្ពស់ | ១៧០ ០០០ |
| ៤៥ | ស្មៀនឃុំ សង្កាត់ | ១៦០ ០០០ |
| ៤៦ | មន្ត្រីក្រមការឬមន្ត្រីបច្ចេកទេសមធ្យម ឬមន្ត្រីក្រមការការបរទេស | ១៦០ ០០០ |

| | | |
|---|---|---|
| ៤៧ | លេខាធិការរដ្ឋបាល ឬមន្ត្រីបច្ចេកទេសបឋម | ១៥០ ០០០ |

## ២. វិស័យអប់រំ

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | សកលវិទ្យាធិការ | ៨៨០ ០០០ |
| ២ | នាយកវិទ្យាស្ថានជាតិអប់រំ | ៨៨០ ០០០ |
| ៣ | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៨៨០ ០០០ |
| ៤ | សកលវិទ្យាធិការរង | ៨២០ ០០០ |
| ៥ | នាយករងវិទ្យាស្ថានជាតិអប់រំ | ៨២០ ០០០ |
| ៦ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៨២០ ០០០ |
| ៧ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៧៩០ ០០០ |
| ៨ | ប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៧៩០ ០០០ |
| ៩ | នាយកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៧៩០ ០០០ |
| ១០ | សាស្ត្រាចារ្យ | ៧៩០ ០០០ |
| ១១ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៧៨០ ០០០ |
| ១២ | សាស្ត្រាចារ្យរង | ៧៥០ ០០០ |
| ១៣ | អនុប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៧០០ ០០០ |
| ១៤ | នាយករងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៧០០ ០០០ |
| ១៥ | សាស្ត្រាចារ្យជំនួយ | ៧០០ ០០០ |
| ១៦ | អធិការមធ្យមសិក្សា | ៤០០ ០០០ |
| ១៧ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៤០០ ០០០ |
| ១៨ | គ្រូឧទ្ទេសឧត្តមសិក្សា (ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៤០០ ០០០ |
| ១៩ | ប្រធានដេប៉ាតឺម៉ង់ | ៣៨០ ០០០ |
| ២០ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ៣៨០ ០០០ |
| ២១ | នាយកសាលាគរុកោសល្យរាជធានី ខេត្ត | ៣៨០ ០០០ |
| ២២ | អនុប្រធានដេប៉ាតឺម៉ង់ | ៣៧០ ០០០ |
| ២៣ | គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅឧត្តមសិក្សា) | ៣៧០ ០០០ |
| ២៤ | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា | ៣៥០ ០០០ |
| ២៥ | នាយករងមជ្ឈមណ្ឌគរុកោសល្យភូមិភាគ | ៣២០ ០០០ |
| ២៦ | នាយកវិទ្យាល័យ | ៣១០ ០០០ |
| ២៧ | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា | ៣០០ ០០០ |
| ២៨ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | ៣០០ ០០០ |
| ២៩ | នាយករងសាលាគរុកោសល្យរាជធានី ខេត្ត | ៣០០ ០០០ |

| | | |
|---|---|---|
| ៣០ | អធិការបឋមសិក្សា | ៣០០ ០០០ |
| ៣១ | នាយករងវិទ្យាល័យ | ២៩០ ០០០ |
| ៣២ | នាយកអនុវិទ្យាល័យ | ២៩០ ០០០ |
| ៣៣ | គ្រូឧទ្ទេសមធ្យមសិក្សាទុតិយភូមិ (ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ២៩០ ០០០ |
| ៣៤ | គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅវិទ្យាល័យ) | ២៨០ ០០០ |
| ៣៥ | នាយករងអនុវិទ្យាល័យ | ២៨០ ០០០ |
| ៣៦ | នាយកសាលាមត្តេយ្យសិក្សា | ២៨០ ០០០ |
| ៣៧ | នាយកសាលាបឋមសិក្សា | ២៨០ ០០០ |
| ៣៨ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាន (ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន) | ២៨០ ០០០ |
| ៣៩ | នាយករងមត្តេយ្យសិក្សា | ២៧០ ០០០ |
| ៤០ | នាយករងសាលាបឋមសិក្សា | ២៧០ ០០០ |
| ៤១ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ២៧០ ០០០ |
| ៤២ | គ្រូឧទ្ទេសបឋម (ក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម) | ២៧០ ០០០ |
| ៤៣ | គ្រូបង្រៀនកម្រិតបឋម | ២៥០ ០០០ |

## ៣. វិស័យសុខាភិបាល

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ (រៀល) |
|---|---|---|
| ១ | នាយកវិទ្យាស្ថានជាតិនៃក្រសួងសុខាភិបាល | ៧៩០ ០០០ |
| ២ | ប្រធានឃ្លាំងឱសថកណ្ដាល | ៧៩០ ០០០ |
| ៣ | នាយកមន្ទីរពេទ្យជាតិ | ៧៩០ ០០០ |
| ៤ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧៩០ ០០០ |
| ៥ | ប្រធានមជ្ឈមណ្ឌលជាតិនៃក្រសួងសុខាភិបាល | ៧៩០ ០០០ |
| ៦ | សាស្ត្រាចារ្យមហាបរិញ្ញា | ៧៩០ ០០០ |
| ៧ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧០០ ០០០ |
| ៨ | នាយករងវិទ្យាស្ថានជាតិនៃក្រសួងសុខាភិបាល | ៧០០ ០០០ |
| ៩ | នាយករងមន្ទីរពេទ្យជាតិ | ៧០០ ០០០ |
| ១០ | អនុប្រធានមជ្ឈមណ្ឌលជាតិ | ៧០០ ០០០ |
| ១១ | អនុប្រធានឃ្លាំងឱសថកណ្ដាល | ៧០០ ០០០ |
| ១២ | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៧០០ ០០០ |
| ១៣ | ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ៦០០ ០០០ |
| ១៤ | វេជ្ជបណ្ឌិតឯកទេស | ៤៥០ ០០០ |
| ១៥ | បណ្ឌិតឱសថសាស្ត្រឯកទេស/ឱសថបណ្ឌិត | ៤៥០ ០០០ |

| | | |
|---|---|---|
| ១៦ | បណ្ឌិតសុខភាពសាធារណៈ | ៤៥០ ០០០ |
| ១៧ | បណ្ឌិតវិទ្យាសាស្ត្រសុខាភិបាល | ៤៥០ ០០០ |
| ១៨ | វេជ្ជបណ្ឌិត(ជំនាញ/អនុបណ្ឌិត) | ៤៣០ ០០០ |
| ១៩ | ទន្តបណ្ឌិតជំនាញ/ទន្តបណ្ឌិតឯកទេស | ៤២០ ០០០ |
| ២០ | វេជ្ជបណ្ឌិត | ៣៦០ ០០០ |
| ២១ | ឱសថការី | ៣៥០ ០០០ |
| ២២ | ទន្តបណ្ឌិត | ៣៥០ ០០០ |
| ២៣ | ប្រធានការិយាល័យស្រុកប្រតិបត្តិ | ៣២០ ០០០ |
| ២៤ | ប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ | ៣២០ ០០០ |
| ២៥ | អនុប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ៣២០ ០០០ |
| ២៦ | នាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៣២០ ០០០ |
| ២៧ | អនុប្រធានការិយាល័យស្រុកប្រតិបត្តិ | ៣១០ ០០០ |
| ២៨ | ឱសថការីមធ្យម | ៣១០ ០០០ |
| ២៩ | គ្រូពេទ្យមធ្យម | ៣១០ ០០០ |
| ៣០ | ទន្តពេទ្យមធ្យម | ៣១០ ០០០ |
| ៣១ | អនុប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ | ២៩០ ០០០ |
| ៣២ | ប្រធានមណ្ឌលសុខភាព | ២៩០ ០០០ |
| ៣៣ | អនុប្រធានមណ្ឌលសុខភាព | ២៨០ ០០០ |
| ៣៤ | គិលានុបដ្ឋាកឯកទេស | ២៨០ ០០០ |
| ៣៥ | គិលានុបដ្ឋាក (បរិញ្ញាបត្រ) | ២៨០ ០០០ |
| ៣៦ | ឆ្មប (បរិញ្ញាបត្រ) | ២៨០ ០០០ |
| ៣៧ | អ្នកព្យាបាលដោយចលនាមធ្យម | ២៧០ ០០០ |
| ៣៨ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | ២៧០ ០០០ |
| ៣៩ | ឆ្មបមធ្យម | ២៧០ ០០០ |
| ៤០ | ទន្តគិលានុបដ្ឋាកមធ្យម | ២៧០ ០០០ |
| ៤១ | គិលានុបដ្ឋាកមធ្យម | ២៧០ ០០០ |
| ៤២ | អ្នកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម | ២៥០ ០០០ |
| ៤៣ | ឆ្មបបឋម | ២៥០ ០០០ |
| ៤៤ | គិលានុបដ្ឋាកបឋម | ២៥០ ០០០ |

**មាត្រា៥ ..**

មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ប៉ុន្តែពុំមានចែងនៅក្នុងអនុក្រឹត្យនេះ នឹងត្រូវផ្តល់ប្រាក់បំណាច់មុខងារផ្អែកលើកម្រិតឋានានុក្រមស្មើឬប្រហាក់ប្រហែលនឹងមុខតំណែងដែលមានកំណត់ក្នុងអនុក្រឹត្យនេះ។

ដោយឡែក ការផ្តល់ប្រាក់បំណាច់មុខតំណែងជូនមន្ត្រីរាជការស៊ីវិល ដែលត្រូវបានតែងតាំងជាទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើគ្រប់ប្រភេទ ត្រូវអនុវត្តអនុលោមបញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ ។

ចាប់ពីអនុក្រឹត្យនេះចូលជាធរមាន រាល់ការកែប្រែនិងការបង្កើតមុខតំណែងថ្មីក្នុងមុខងារសាធារណៈរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦ ..**

មន្ត្រីរាជការស៊ីវិលក្នុងវិស័យរដ្ឋបាល អប់រំ សុខាភិបាល បច្ចេកទេស និងការទូត ដែលត្រូវបានតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធនៃក្រសួង ស្ថាប័ន ត្រូវទទួលបានប្រាក់បំណាច់មុខងារផ្អែកលើប្រភេទក្របខណ្ឌប្រសិនបើប្រាក់បំណាច់មុខងារនៃមុខតំណែងនោះមានកម្រិតទាបជាង។

**មាត្រា៧ ..**

មន្ត្រីរាជការស៊ីវិលដែលក្រសួង ស្ថាប័ន អនុញ្ញាតឬចាត់បញ្ជូនឱ្យទៅបន្តការសិក្សា ឬបណ្តុះបណ្តាល ឬបំពេញបេសកកម្មក្នុងនិងក្រៅប្រទេសតាមតម្រូវការនៃមុខងារ មានសិទ្ធិទទួលបៀវត្សក្នុងរយៈពេលកំណត់ដែលមានការសម្រេចដោយក្រសួង ស្ថាប័នសាមី។

**មាត្រា៨ ..**

មន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្នុងកម្មសិក្សា ត្រូវបានផ្តល់ប្រាក់បំណាច់មុខងារស្របតាមប្រភេទក្របខណ្ឌរបស់ខ្លួន។

**មាត្រា៩ ..**

មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល ទាំងវគ្គសិស្សមន្ត្រីជាន់ខ្ពស់និងសិស្សមន្ត្រីក្រមការ ចាប់ពីពេលបំពេញកម្មសិក្សានៅតាមក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវទទួលប្រាក់បំណាច់មុខងារ ដូចមានកំណត់ខាងក្រោម៖

- ចំពោះមន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីជាន់ខ្ពស់ ទទួលបានប្រាក់បំណាច់មុខងារអនុប្រធាននាយកដ្ឋាន
- ចំពោះមន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល វគ្គសិស្សមន្ត្រីក្រមការ ទទួលបានប្រាក់បំណាច់មុខងារអនុប្រធានការិយាល័យថ្នាក់កណ្តាល។

**មាត្រា១០ ..**

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

**មាត្រា១១ ..**

ប្រាក់បំណាច់មុខងារដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ តទៅ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា១២ ..**

រាល់ការតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន នៅកម្រិតអនុប្រធានឬថ្នាក់ប្រហាក់ប្រហែលចាប់ពីមុខតំណែងអគ្គលេខាធិការរងក្រសួង ស្ថាប័ន រហូតដល់មុខតំណែងនៅកម្រិតអនុប្រធានឬថ្នាក់ប្រហាក់ប្រហែលទាបបំផុតក្នុងមុខងារសាធារណៈ មិនត្រូវបានអនុញ្ញាតឡើយ រហូតដល់ក្រសួង ស្ថាប័ន បានកំណត់និងរៀបចំមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន បានពេញលេញនិងរួចរាល់ លើកលែងក្រសួង ស្ថាប័ន ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ត្រូវបានកំណត់ចំនួនច្បាស់លាស់រួចហើយដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងការសម្រេចរបស់រាជរដ្ឋាភិបាល។

ក្រសួង ស្ថាប័ន ត្រូវកំណត់និងរៀបចំមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងឱ្យបានច្បាស់លាស់និងពេញលេញផ្អែកលើស្ថានភាពនៃក្រសួង ស្ថាប័ននីមួយៗ ដោយសហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានរួចរាល់មុនដំណាច់ឆ្នាំ២០១៥។

ការរៀបចំមុខតំណែងនិងចំនួននៃមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៣ ..**

អនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនិងប្រាក់កម្រៃគរុកោសល្យក្នុងវិស័យអប់រំ អនុក្រឹត្យលេខ៩៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែប្រែប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការកំណត់ប្រាក់បំណាច់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការស៊ីវិលដែលបានបញ្ចប់ការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល អនុក្រឹត្យលេខ ២៤៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងអប់រំ យុវជន និងកីឡា អនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ